## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

* * * *** * * * * *

## កិច្ចព្រមព្រៀង
## រវាង
## ក្រុមហ៊ុន ស៊ី.អេហ្វ.ស៊ី ហ្គាម៉ិន ភីធីអ៊ីយ ឯ.ក
## ជាមួយតំណាងកម្មករប្រតិភូបុគ្គលិក និងប្រធានក្រុម ប្រចាំក្រុមហ៊ុន

នៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០២២ វេលាម៉ោង ០៣ និង ០០ នាទី រសៀល នៅក្នុងរោងចក្រ

**ស៊ី.អេហ្វ.ស៊ី ហ្គាម៉ិន ភីធីអ៊ីយ ឯ.ក**

មានកិច្ចប្រជុំមួយរវាងតំណាងក្រុមហ៊ុន និងតំណាងកម្មករ និយោជិក ។

នៅក្នុងអង្គប្រជុំនេះ នាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិកទាំងអស់ស្តីពីស្ថានភាពបច្ចុប្បន្ននៃក្រុមហ៊ុនដែលខ្វះអ្នកបញ្ជាទិញដែលបណ្តាលឲសង្វាក់ផលិកម្មត្រូវផ្អាកដំណើរការ ។ ហេតុដូចនេះក្រុមហ៊ុនសម្រេចចិត្តព្យួរកិច្ចសន្យាការងាររបស់កម្មករ និយោជិកចំនួន ៥៣ នាក់ (ស្រី ៣៦ នាក់) ក្នុងចំណោមកម្មករនិយោជិកសរុបចំនួន ៤៨២ នាក់ ( ស្រី ៣៤៥ នាក់) រយះពេល ៣០ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០២២ ដល់ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០២២ ។ ហើយក្នុងកំឡុងពេលព្យួរកាងារនេះកម្មករនិយោជិកបានឯកភាពទទួលការផ្តល់ជូនរបស់ក្រុមហ៊ុននូវប្រាក់ឧត្តម្ភ ៣៥ ដុល្លាក្នុងមួយខែ។

ប្រាក់ឧត្តម្ភក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងារនេះនិងបើកជូនបងប្អូនកម្មករនៅថ្ងៃទី ១០ ។

អង្គប្រជុំបានចប់នៅវេលាម៉ោង ០៣ និង ៣០ នាទី រសៀលនាថ្ងៃខែឆ្នាំដដែលប្រកបដោយបរិយាកាសរីករាយនិងស្និតស្នាលក្រោមស្មារតីទទួលខុសត្រូវខ្ពស់ និងយោគយល់សហការគ្នាយ៉ាងរលូន ។

ថ្ងៃព្រហស្បតិ៍ ០៣កើត ខែកត្តិក ឆ្នាំ ខាល ចត្វាស័ក ពុទ្ធសករាជ ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០២២

**តំណាងក្រុមហ៊ុន**

**ស្នាមមេដៃតំណាងកម្មករ និយោជិក**

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន ស៊ី.អេហ្វ.ស៊ី ហ្គាម៉ិន ភីធីអ៊ីយ ឯ.ក C.F.C GARMENT PTY CO.,LTD. KINGDOM OF CAMBODIA



**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**នាយកក្រុមហ៊ុន ស៊ី.អេហ្វ.ស៊ី ហ្គាមិន ភីធីវ៉ាយ ៦.ក**

C.F.C GARMENT PTY CO., LTD

**សូមគោរពជូន**

**លោកប្រធាននាយកដ្ឋានអធិការកិច្ចការងារ**

**កម្មវត្ថុ៖** ស្តីពីការព្យួរកិច្ចសន្យាការងារកម្មករនិយោជិករយៈពេល៣០ថ្ងៃ ចាប់គិតពីថ្ងៃទី០៥ខែវិច្ឆិកាឆ្នាំ ២០២២ ដល់ ថ្ងៃទី០៤ខែធ្នូឆ្នាំ ២០២២ ។

**យោង៖** មាត្រា៧១ និងមាត្រា៧២ នៃច្បាប់ស្តីពីការងារ ។

សេចក្តីដូចបានចែងក្នុងកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជម្រាបជូន **លោកប្រធាន** មេត្តាជ្រាបថា បច្ចុប្បន្នក្រុមហ៊ុន យើងខ្ញុំកំពុងជួបការលំបាកផ្នែកហិរញ្ញវត្ថុ ដោយសារមិនមានការបញ្ជាទិញគ្រប់គ្រាន់ ព្រោះវិបត្តិសកល សេដ្ឋកិច្ច ដូច្នេះក្រុមហ៊ុនមិនមានការងារគ្រប់គ្រាន់សម្រាប់បងប្អូននិយោជិកធ្វើឡើយ។ ដូច្នេះក្រុមហ៊ុនសូមព្យួរកិច្ចសន្យាការងារកម្មករនិយោជិកសរុបចំនួន ៥៣ នាក់ (ស្រី ៣៦ នាក់) ដោយ ចាប់គិតពីថ្ងៃទី ០៥ ខែវិច្ឆិកា ឆ្នាំ ២០២២ ដល់ ថ្ងៃទី០៤ ខែធ្នូ ឆ្នាំ ២០២២ ។

អាស្រ័យហេតុនេះ សូម **លោកប្រធាន** មេត្តាអនុញ្ញាតឲក្រុមហ៊ុនយើងខ្ញុំបានព្យួរកិច្ចសន្យាការងារកម្មករនិយោជិកដោយក្តីអនុគ្រោះ ។

សូម **លោកប្រធាន** ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

ថ្ងៃព្រហស្បតិ៍ ០៣កើត ខែកត្តិក ឆ្នាំ ខាល ចត្វាស័ក ពុទ្ធសករាជ ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០២២

**នាយកក្រុមហ៊ុន**

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន ស៊ី.អេហ្វ.ស៊ី ហ្គាមិន ភីធីវ៉ាយ ៦.ក C.F.C GARMENT PTY CO.,LTD. KINGDOM OF CAMBODIA